# របាយការណ៍បូកសរុប
# របស់ឯកឧត្តមបណ្ឌិត ហ៊ើល ចំរើន អនុរដ្ឋលេខាធិការ
# និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
# ថ្លែងនៅក្នុង វេទិកាស្តីពី "មុខងារនីតិកម្មនិងការងារកែទម្រង់របស់រាជរដ្ឋាភិបាល"

ថ្ងៃអង្គារ ១៣ កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
សណ្ឋាគារសុខាភ្នំពេញ, រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩

- ជាបឋម ខ្ញុំបាទសូមថ្លែងគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុត ជូន **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការ**ជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** ជាទីគោរពប្រណិប័តន៍ដ៏ខ្ពង់ខ្ពស់បំផុត!
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំតំណាងក្រសួង ស្ថាប័ន ក្រុមប្រឹក្សាធម្មនុញ្ញ ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិការ ស្ថាប័នតុលាការ រដ្ឋបាលថ្នាក់ជាតិ ថ្នាក់កណ្តាល ថ្នាក់មូលដ្ឋាន ថ្នាក់ក្រោមជាតិ សាលាភូមិន្ទរដ្ឋបាល រាជបណ្ឌិត្យសភាកម្ពុជា គ្រឹះស្ថានឧត្តមសិក្សា ជាទីគោរពដ៏ជ្រាលជ្រៅបំផុត!**

វេទិកាស្តីពី "**មុខងារនីតិកម្មនិងការងារកែទម្រង់របស់រាជរដ្ឋាភិបាល**" ដែលបានដំណើរការប្រព្រឹត្តទៅ តាមរបៀបវារៈដែលបានកំណត់ រយៈពេលពេញមួយថ្ងៃ រហូតមកដល់នាទីនេះ អាចកំណត់ទុកថាជាជោគជ័យដ៏ប្រពៃថ្លៃថ្លាមួយ និងប្រកបដោយលក្ខណៈសម្បត្តិពោរពេញដោយសិរីសួស្តី ក្នុងបរិយាកាសគួរជាទីលើកទឹកចិត្តដ៏រំភើបក្រៃលែង ដោយទទួលបានអធិបតីភាពដ៏ខ្ពង់ខ្ពង់បំផុត របស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលបានឆ្លៀតពេលវេលាដ៏មមាញឹកនិងកាត់ថ្លៃមិនបាន អញ្ជើញផ្តល់កិត្តិយសដ៏ឧដុង្គឧត្តម និងការគាំទ្រដ៏រឹងមាំ ដល់គំនិតផ្តួចផ្តើមអំពីទំនាក់ទំនងរវាងមុខងារនីតិកម្មនិងការងារកែទម្រង់របស់រាជរដ្ឋាភិបាល។

ខ្ញុំពិតជាមិនរារែកនឹងសារភាព ជូន **សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី** និងអង្គវេទិកា ទេថាខ្ញុំបាទពុំមានលទ្ធភាពរៀបរាប់ឱ្យបានក្បោះក្បាយនិងគ្រប់ជ្រុងជ្រោយ អំពីលទ្ធផលដ៏សម្បូរបែបនៃវេទិកាលើកដំបូង ស្តីពីមុខងារនីតិកម្មនិងការងារកែទម្រង់របស់រាជរដ្ឋាភិបាល ដែលបាននិងកំពុងដក់ជាប់ចូលយ៉ាងជ្រៅនិងច្រើនអន្លើ ទៅក្នុងដួងចិត្ត ដួងគំនិត និងដួងបញ្ញា របស់សមាជិក សមាជិកា នៃអង្គវេទិកា រយៈពេលមួយថ្ងៃនេះ។

ខ្ញុំសូមឧត្តមានុញ្ញាតជម្រាបជូន **សម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី** និងអង្គវេទិកា អំពីលទ្ធផលគន្លឹះដែលសមប្រកបដោយសម្បត្តិ ៣ ប្រការ ដូចតទៅ÷ ទី១. សម្បត្តិប្រណិប័តន៍ ទី២. សម្បត្តិត្រីគុណ និងទី៣. សម្បត្តិវាសនា។

## សម្បត្តិទី១. គឺសម្បត្តិនៃការប្រណិប័តន៍

អង្គវេទិកា បានដំណើរការប្រព្រឹត្តទៅ ដោយប្រតិបត្តិបានយ៉ាងត្រឹមត្រូវ តាមរបៀបវារៈដែលចែកចេញជា ២ វគ្គ គឺពេលព្រឹក ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានគូសវាសក្របខណ្ឌនិងទិសដៅយុទ្ធសាស្ត្រ ដែលត្រូវបានក្លាយជាមូលដ្ឋាននៃការពិនិត្យ ពិចារណា និងបញ្ជាក់បន្ថែម តាម

រយៈបទបង្ហាញចំនួន ៥ រៀបចំដោយតំណាងក្រសួងផែនការ ក្រសួងយុត្តិធម៌ ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងពិភាក្សាយ៉ាងសកម្ម និងស៊ីជម្រៅ ក្រោមការដឹកនាំនិងសម្របសម្រួលដោយ **ឯកឧត្តមរដ្ឋលេខាធិការប្រចាំការ វង្សី វិស្សុត** នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នៅវគ្គរសៀល ក្រុមពិភាក្សាទាំង៥ បានយកប្រធានបទនិងគតិពិភាក្សាកាលពីព្រឹក ទៅជជែកលម្អិត នៅក្នុងក្រុមពិភាក្សា រៀងៗខ្លួន យ៉ាងលម្អិតនិងតាមបរិបទនៃកិច្ចការនីតិកម្មនិងការងារកែទម្រង់ តាមវិស័យទាំង៥ បន្ថែមទៀត ក្នុងគោលដៅវិភាគស៊ីជម្រៅ និងទាញចេញជាគំនិតផ្តួចផ្តើមថ្មីៗ យកមកបង្ហាញក្នុងកិច្ចពិភាក្សាទូលំទូលាយ ក្រោមការដឹកនាំនិងសម្របសម្រួលដោយ **ឯកឧត្តម យក់ ប៊ុនណា** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ។

**សម្បត្តិទី២. គឺសម្បត្តិត្រីគុណ**

អង្គវេទិកាទាំងមូល បានពិចារណា ពិភាក្សា និងស្វែងយល់ យ៉ាងស៊ីជម្រៅនិងទូលំទូលាយអំពីគុណតម្លៃ ៣ ប្រការ នៃមុខងារនីតិកម្ម គឺ គុណសម្បត្តិ គុណាធិបតេយ្យ និងគុណប្រយោជន៍ នៃការបំពេញមុខងារនីតិកម្ម សម្រាប់គាំទ្រការងារកែទម្រង់។

ជាគុណសម្បត្តិ អ្នកច្បាប់ ឬអ្នកបំពេញមុខងារនីតិកម្ម ក្រោមទម្រង់ជាក្រុមប្រឹក្សា អគ្គនាយកដ្ឋាន នាយកដ្ឋាន ឬអង្គភាពនានាដែលទទួលមុខងារនីតិកម្ម គប្បីសម្បូរកបដោយលក្ខណៈសម្បត្តិ ជាគុណធម៌ ៣ ប្រការ គឺ ចេះ ចង់ និង ធ្វើ។ ចេះ រហូតដល់អស់ចំណេះ ចង់រហូតដល់អស់ចំណង់ និងធ្វើរហូតដល់អស់អំពើ។ អន្លង់វិបត្តិ៣ យ៉ាង នៃមុខងារនីតិកម្ម គឺ ១. អ្នកចេះ មិនចង់ធ្វើ ២. អ្នកចេះ ចង់ តែមិនធ្វើ និង៣. អ្នកមិនចេះ តែចង់ធ្វើ។ គុណសម្បត្តិទាំង ៣ ប្រការ គប្បីមានព្រមគ្នា ទើបមុខងារនីតិកម្មអាចផ្លាស់ទីខ្លួនបាន ទៅគាំទ្រប្រសិទ្ធភាពនៃការកែទម្រង់។

ក្នុងទស្សនៈនេះ ការដឹកនាំរបស់ស្ថាប័ន គឺជាកត្តាគន្លឹះ ក្នុងការជៀសផុតពីអន្លង់វិបត្តិនេះ ដែលគប្បីពិនិត្យលើគុណតម្លៃទី២គឺ គុណាធិបតេយ្យ។ នេះជាមាគ៌ាដឹកនាំមួយដែលយកគុណសម្បត្តិ សារៈសំខាន់ និងសមិទ្ធផលជាក់ស្តែងជាគោលការណ៍ដឹកនាំ ដោយថ្លែងប្រមាណ ឱ្យមានតុល្យភាពរវាងសិទ្ធិអំណាច និងការទទួលខុសត្រូវ, ផលប្រយោជន៍ និងគុណប្រយោជន៍, តុល្យភាពនៃការគ្រប់គ្រងជំនាញនិងនីត្យានុកូលភាព ក្នុងគោលដៅធានាប្រសិទ្ធភាពនៃអភិបាលកិច្ច តុល្យភាពនៃការគ្រប់គ្រង និងស្ថិរភាព និងចីរភាពនៃការដឹកនាំស្ថាប័ន។

គុណតម្លៃទី៣ គឺគុណប្រយោជន៍នៃមុខងារនីតិកម្ម ក្នុងការធានានីត្យានុកូលភាព និងនីត្យានុភាព (អានុភាពនៃច្បាប់) នៃអភិបាលកិច្ចនិងការកែទម្រង់។ ប្រសិទ្ធភាពនៃការកែទម្រង់អាចពឹងផ្អែកមួយចំណែកធំ លើគុណភាពនៃការតាក់តែងច្បាប់ និងឥរិយាបថត្រឹមត្រូវប្រកបដោយគុណធម៌ នៃការអនុវត្តច្បាប់។ ច្បាប់មានគុណភាព អនុវត្តច្បាប់ខ្វះឥរិយាបថត្រឹមត្រូវ អាចរងទុក្ខពីការស្តីបន្ទោសរបស់ស្ថាប័ន រីឯ ច្បាប់ខ្វះគុណភាព អនុវត្តច្បាប់ប្រកបដោយឥរិយាបថត្រឹមត្រូវ ក៏អាចរងទុក្ខពីបណ្តាសាប្រជារាស្ត្រ ផងដែរក៏មិនដឹង។ ហេតុនេះ ច្បាប់មានគុណភាព និងច្បាប់អនុវត្តប្រកបដោយឥរិយាបថត្រឹមត្រូវមានគុណធម៌ ទើបអាចធានាបាននូវនីត្យានុកូលភាព និងនីត្យានុភាពនៃអភិបាលកិច្ចនិងប្រសិទ្ធភាព ផលិតភាព និងស័ក្តិសិទ្ធភាពនៃការកែទម្រង់។

**សម្បត្តិទី៣. គឺសម្បត្តិវាសនា**

អង្គពិភាក្សា នៃអង្គវេទិកា បានមូលមតិគ្នាស្នើឡើងនូវវិធានការគន្លឹះមួយចំនួន ដើម្បីគោរពស្នើសុំការដឹកនាំនិងការសម្រេចដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចក្រឡាហោមខបនាយករដ្ឋមន្ត្រី** ដូចតទៅ÷

ទី១. ព្រមជាមួយនឹងការគូសបញ្ជាក់ពីក្រុមពិភាក្សាទាំង៥ អំពីសារៈសំខាន់ និងភាពចាំបាច់នៃមុខងារនីតិកម្ម គាំទ្រការងារកែទម្រង់ ស្នើសុំគាំទ្រឱ្យមានវេទិកាស្តីពីមុខងារនីតិម្ម និងការងារកែទម្រង់នេះ នៅឆ្នាំក្រោយទៀត។

ទី២. ស្នើសុំឱ្យក្រុមប្រឹក្សានីតិកម្ម នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋានកែទម្រង់ទាំង៤ សហការ សម្របសម្រួល និងរៀបចំផែនការបូកសរុបលទ្ធផលនៃអង្គវេទិកានេះ ដើម្បីរៀបចំវិធានការអនុវត្តជាក់ស្តែងឱ្យមានប្រសិទ្ធភាព ដោយមានការគាំទ្រពីគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងគណៈកម្មាធិការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។

ទី៣. ស្នើសុំពិនិត្យ និងរៀបចំចក្ខុវិស័យនិងយុទ្ធសាស្ត្ររួមសម្រាប់មុខងារនីតិកម្មគាំទ្រដល់ការងារកែទម្រង់ កម្រិតរាជរដ្ឋាភិបាល ជាមួយនឹងយន្តការអន្តរស្ថាប័ន សម្រាប់ដឹកនាំការងារនីតិកម្ម កម្រិតរាជរដ្ឋាភិបាល ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តមុខងារនីតិកម្ម ជាអន្តរស្ថាប័ន សំដៅគាំទ្រដល់ការកែទម្រង់ជាអន្តរវិស័យ ឬអន្តរការដ្ឋានកែទម្រង់។

សុន្ទរកថាគន្លឹះ/បិទអង្គវេទិកា ដែលនឹងថ្លែង/ប្រកាស ដ៏កក់ក្តៅនិងថ្លៃថ្លាបំផុត ដោយ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការ**ជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** នាពេលបន្តិចទៀតនេះ នឹងកំណត់ជោគវាសនា មួយចំណែកធំ នៃទំនាក់ទំនងរវាងការងារនីតិកម្មនិងការងារកែទម្រង់របស់រាជរដ្ឋភិបាល ដើម្បីជាឧត្តមប្រយោជន៍ដល់ការសម្រេចចក្ខុវិស័យ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ទាំងសម្រាប់ ឆ្នាំ២០៣០ ទាំងសម្រាប់ឆ្នាំ២០៥០ និងជានិច្ចនិរន្តរ៍តរៀងទៅ។

នៅក្នុងបរិយាកាសដ៏ថ្លៃថ្លានិងមនោសញ្ចេតនាដ៏កក់ក្តៅនេះ ខ្ញុំបាទ ក្នុងនាមអង្គវេទិកាទាំងមូល មានកិត្តិយសដ៏ឧដុង្គឧត្តមនិងវិសេសក្រៃលែង សូមឧត្តមានុញ្ញាតគោរពអញ្ជើញ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សូមលោកមេត្តាឡើងថ្លែងសុន្ទរកថាបិទ វេទិកាស្តីពី “**មុខងារនីតិកម្មនិងការងារកែទម្រង់របស់រាជរដ្ឋាភិបាល**”។

**សូមគោរពអញ្ជើញ និងសូមអរគុណ!**